**Regular School Attendance**

# ការទៅសាលារៀនឲ្យបានទៀងទាត់

## ពត៌មានសំរាប់មាតាបិតា និងអ្នកមើលថែ







## តើលោកអ្នកដឹងឬទេ? ប្រសិនបើសិស្សខកខានមិនបានទៅរៀនយ៉ាងតិចណាស់៨ថ្ងៃក្នុងមួយឆមាសសាលា ទំរាំតែដល់ពេលចប់សាលាបឋមសិក្សា នោះគេនឹងត្រូវខកខានការសិក្សាចំនួនមួយឆ្នាំ។

### ហេតុអ្វីបានជាខ្ញុំត្រូវបញ្ជូនកូនរបស់ខ្ញុំទៅសាលារៀន?

ការសិក្សានៅរដ្ឋញូវសៅវែលគឺជាការខានពុំបាន។ នេះមានន័យថា កុមារទាំងអស់ដែលមានអាយុចាប់ពីប្រាំមួយឆ្នាំ ហើយនៅក្រោមអាយុបញ្ចប់ការសិក្សាយ៉ាងតិចបំផុត បានតម្រូវតាមច្បាប់ឲ្យទៅសាលារៀន។

ចាប់ពីឆ្នាំ២០១០ សិស្សរដ្ឋញូវសៅវែលទាំងអស់ត្រូវរៀនបញ្ចប់ Year 10។ បន្ទាប់ពី Year 10 ហើយរហូតទាល់តែគេចូលអាយុ១៧ឆ្នាំ សិស្សត្រូវតែ:

១. នៅសាលារៀន ឬសាលារៀនតាមផ្ទះដែលចុះឈ្មោះស្របច្បាប់ ឬ

២. នៅវិទ្យាស្ថានអប់រំ ឬហ្វឹកហ្វឺនដែលរដ្ឋយល់ព្រម (ឧទាហរណ៍ TAFE ការហាត់រៀនធ្វើការ ការហាត់រៀនធ្វើកូនជាង) ឬ

៣. ស្ថិតនៅពេញពេល ក្នុងការងារមានប្រាក់បៀវត្សរ៍ (ជាមធ្យម២៥ម៉ោងក្នុង១អាទិត្យ) ឬរួមផ្សំគ្នានឹងការងារ ការអប់រំ និង/ឬហ្វឹកហ្វឺន។

នាយកសាលាត្រូវទទួលខុសត្រូវស្របច្បាប់ ចំពោះការរក្សាកំណត់ត្រាឲ្យបានត្រឹមត្រូវនៃសិស្សដែលមករៀន។

នាយកសាលាក៏ត្រូវទទួលខុសត្រូវផងដែរ ក្នុងការសំរេចពីមូលហេតុដែលបានផ្តល់ឲ្យ អំពីការមិនបានមករៀនរបស់សិស្ស ថាតើសមហេតុផលឬទេ។

ដោយហេតុនេះ នាយកសាលាអាចសួររកសំបុត្រពេទ្យ ឬឯកសារដទៃទៀត ចំពោះការមិនបានមករៀនក្នុងរយៈពេលយូរ ឬញឹកញាប់ដែលបានពន្យល់ប្រាប់ដោយមាតាបិតាថាកុមារមានជម្ងឺ។

ប្រសិនបើនាយកសាលាពុំចាត់ទុកថាការពន្យល់ប្រាប់នោះជាទីពេញចិត្តទេ គេនឹងកត់ត្រាអំពីការមិនបានមករៀនថាពុំសមហេតុផល។

នេះគឺជាការសំខាន់ដែលត្រូវយល់ថា New South Wales Department of Education and Training (ក្រសួងអប់រំ និងហ្វឹកហ្វឺនរដ្ឋញូវសៅវែល) អាចកាត់ទោសមាតាបិតា (រួមទាំងអ្នកមើលថែ) ប្រសិនបើក្មេងដែលមានអាយុត្រូវទៅសាលារៀនខកខានមិនបានមករៀន ឬមានថ្ងៃមិនបានមករៀនពុំសមហេតុផលមួយចំនួន។

### តើខ្ញុំត្រូវបញ្ជូនកូនរបស់ខ្ញុំទៅសាលារៀនជារៀងរាល់ថ្ងៃឬ?

**ប្រាកដណាស់។** នេះគឺជាល័ក្ខខ័ណ្ឌនៃការចុះឈ្មោះចូលរៀន ដែលលោកអ្នកត្រូវបញ្ជូនកូនរបស់លោកអ្នកទៅរៀនឲ្យបានរៀងរាល់ថ្ងៃ។

ការមិនបានមករៀនមួយចំនួនតូច អាចចាត់ទុកថាជាការសមហេតុផលប្រសិនបើកូនរបស់លោកអ្នក:

- ត្រូវទៅពិធីបុណ្យសាសនាពិសេសណាមួយ
- តម្រូវឲ្យទៅចូលរួមក្នុងស្ថានភាពគ្រួសារដ៏ធ្ងន់ធ្ងរ និង / ឬជាបន្ទាន់ (ឧទាហរណ៍ បុណ្យសព)
- ឈឺខ្លាំងមិនអាចទៅសាលារៀន ឬមានជម្ងឺឆ្លង។

មានហ្វូងចៃនៅលើក្បាលអាចជាការកើតមានទូទៅជាពិសេសនៅសាលាបឋមសិក្សា។ មាតាបិតាគួរពិនិត្យមើលសក់ក្បាលកូនរបស់គេឲ្យបានទៀងទាត់ ដើម្បីរកមើលចៃក្បាល ហើយចាត់វិធានការព្យាបាលពេលណារកឃើញពងចៃ ឬចៃក្បាល។

ពត៌មានបកប្រែភាសាអំពីចៃក្បាល និងរបៀបព្យាបាលចៃក្បាលអាចទទួលយកបាននៅតាមវ៉ិបសាយ: https://www.det.nsw.edu.au/languagesupport/documents/headlice/infosheet.htm

ឱវាទពីក្រសួងសុខាភិបាលរដ្ឋញូវសៅវែល (NSW Health) បញ្ជាក់ឲ្យដឹងថាពុំចាំបាច់បញ្ជូនសិស្សឲ្យទៅផ្ទះវិញឡើយ ឬហាមមិនឲ្យចូលសាលារៀនដោយព្រោះគេមានចៃក្បាលនោះទេ។ ចៃក្បាលពុំមែនជាមូលហេតុដែលយកជាការបាន សំរាប់ការបន្ទាយពេលមិនទៅរៀននោះទេ។

### ហេតុអ្វីបានជាការទៅសាលារៀនឲ្យបានទៀងទាត់ជាការសំខាន់?

ការទៅសាលារៀនឲ្យបានទៀងទាត់ នឹងជួយកូនរបស់លោកអ្នកឲ្យមានជោគជ័យក្នុងជីវិតទៅអនាគត។

ការទៅសាលារៀនរៀងរាល់ថ្ងៃ នាំឲ្យការរៀនសូត្រកាន់តែងាយស្រួលសំរាប់កូនរបស់លោកអ្នក ហើយជួយក្មេងឲ្យបង្កើត និងរក្សាមិត្តភាពជាមួយក្មេងឯទៀត។

ប្រសិនបើកូនរបស់លោកអ្នកពុំបានរៀនមុខជំនាញចាំបាច់នៅឆ្នាំចូលសាលារៀនពីដំបូង គេអាចបង្កើតបញ្ហារៀនសូត្រនៅឆ្នាំក្រោយទៀត។

NEW SOUTH WALES DEPARTMENT OF EDUCATION AND TRAINING

## ហេតុអ្វីបានជាការមកដល់សាលារៀនទាន់ពេលជាការសំខាន់?

ការមកសាលារៀន និងថ្នាក់រៀនទាន់ពេលៈ

- ដើម្បីប្រាកដថាកូនរបស់លោកអ្នកពុំបានខកខានធ្វើសកម្មភាពរៀនសូត្រ សំខាន់ដែលបានគ្រោងទុកនៅពេលមុនដំបូងក្នុងថ្ងៃរៀន ដែលភាគច្រើនគេបានប្រុងប្រៀបស្មារតីទុកជាមុន។
- ជួយកូនរបស់លោកអ្នកឲ្យរៀនដឹងអំពីសារៈសំខាន់នៃការមករៀនទាន់ពេល និងការធ្វើតាមទម្លាប់
- ផ្តល់ឲ្យកូនរបស់លោកអ្នកមានពេលដើម្បីរាក់ទាក់មិត្តភក្តិរបស់គេ មុនថ្នាក់រៀនចាប់ផ្តើម ហើយដោយហេតុនេះ
- បន្ថយនូវឱកាសរំខានដល់ថ្នាក់រៀន។

ការមកសាលារៀនយឺតពេល ត្រូវបានកត់ត្រាទុកថាដូចមិនបានមករៀនពុំពេញថ្ងៃដែរ ហើយត្រូវពន្យល់ទៅសាលារៀន តាមរបៀបដូចគ្នានឹងសណ្ឋាននៃការមិនបានមករៀនដទៃទៀតដែរ។

## តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើគ្រួសាររបស់យើងត្រូវធ្វើដំណើរទៅសំរាកលំហែក្នុងពេលម៉ោងសាលា?

មាតាបិតា និងអ្នកមើលថែត្រូវបានលើកទឹកចិត្តមិនឲ្យយកកូនរបស់គេចេញពីសាលារៀន ដើម្បីការសំរាកលំហែរបស់គ្រួសារឡើយ។ ជាជំនួសវិញនោះ គ្រួសារត្រូវខិតខំសំរួលការសំរាកលំហែ ក្នុងពេលវិស្សមកាលសាលា។

ប្រសិនបើការសំរាកលំហែរបស់គ្រួសារលោកអ្នកត្រូវធ្វើឡើងចំរយៈពេលម៉ោងសាលា សូមផ្តល់ព័ត៌មានទៅនាយកសាលាជាមុន ហើយស្នើសុំការឈប់សំរាក និង / ឬការលើកលែងពីសាលា។ អាស្រ័យទៅលើស្ថានភាពការឈប់សំរាក និងមានរយៈពេលយូរយ៉ាងណាដែរនោះ លោកអ្នកអាចស្នើសុំឲ្យសាលារៀនផ្តល់កិច្ចការសាលា ដែលត្រូវបំពេញក្នុងពេលដែលកូនរបស់លោកអ្នកមិនបានទៅរៀន។

## តើកូនរបស់ខ្ញុំត្រូវទៅចូលរួមនៅក្នុងគ្រប់ទាំងសកម្មភាពមានរួមទាំងការហាត់ឲ្យរាងកាយមាំមួន និងកីឡាប្រចាំថ្ងៃឬ?

**ប្រាកដណាស់។** កីឡា និងសកម្មភាពផ្នែករាងកាយដទៃទៀត ជួយរក្សាឲ្យកូនរបស់លោកអ្នកមានសុខភាពល្អ។ ក្មេងត្រូវបានរំពឹងទុកឲ្យចូលរួមក្នុងគ្រប់ទាំងសកម្មភាពសាលាយ៉ាងទៀងទាត់ មានរួមទាំងកីឡា។

## សូមកុំឲ្យកូនរបស់លោកអ្នកមិនមករៀន ដោយសារព្រឹត្តិការណ៍ដូចតទៅនេះៈ

- បុណ្យខួបកំណើត
- ការទៅផ្សារ
- នៅមើលថែក្មេងដទៃទៀត
- ការពិនិត្យសុខភាពតាមទម្លាប់ ឬការមើលថែខ្លួនដូចជាការកាត់សក់
- ព្រឹត្តិការណ៍បន្តិចបន្តួចក្នុងគ្រួសារ
- ការដេកជ្រុលម៉ោង។

ការណាត់ជួបផ្នែកពេទ្យ និងផ្នែកសុខភាពដទៃទៀតសំរាប់កូនរបស់លោកអ្នកត្រូវធ្វើមុន ឬក្រោយម៉ោងសាលា ឬក្នុងពេលវិស្សមកាលសាលា។

## តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើកូនរបស់ខ្ញុំត្រូវនៅឆ្ងាយពីសាលារៀន?

ប្រសិនបើកូនរបស់លោកអ្នកត្រូវនៅឆ្ងាយពីសាលារៀននេះគឺជាការសំខាន់ដែលត្រូវប្រាប់សាលារៀន ហើយផ្តល់មូលហេតុដែលកូនរបស់លោកអ្នកមិនបានមករៀន។ ដើម្បីពន្យល់ប្រាប់ពីការមិនបានមករៀន មាតាបិតា និងអ្នកមើលថែអាចៈ

- ផ្ញើលិខិតខ្លី ទូរសារ ឬអ៊ីម៉េលមកសាលារៀន
- ទូរស័ព្ទមកសាលារៀន ឬ
- មកជួបសាលារៀន។

គ្រប់ទាំងការមិនបានមកសាលារៀន ត្រូវតែពន្យល់ប្រាប់ទៅសាលារៀន។ លោកអ្នកអាចរកឃើញកំណត់ហេតុនៃសិស្សមិនបានមករៀនជាពីរភាសា និងព័ត៌មានបន្ថែមអំពីការមករៀន នៅតាមវ៉ិបសាយរបស់ក្រសួងនៅក្រោមចំណងជើង School Attendance (ការទៅសាលារៀន)ៈ https://www.det.nsw.edu.au/languagesupport/documents/index_s.htm

នាយកសាលាមានសិទ្ធិសួរមាតាបិតា ឬអ្នកមើលថែចំពោះការស្នើសុំមិនឲ្យកូនរបស់គេមករៀន។

នាយកសាលាក៏អាចសាកសួរឲ្យមានការពន្យល់ប្រាប់ណាមួយផងដែរ អំពីការមិនបានមករៀនរបស់ក្មេង។

## បើកូនរបស់ខ្ញុំនឹងមិនព្រមទៅសាលារៀនទេ តើខ្ញុំត្រូវធ្វើដូចម្តេច?

លោកអ្នកត្រូវទាក់ទងជាមួយនាយកសាលាឲ្យបានឆាប់តាមអាចធ្វើបាន ដើម្បីពិភាក្សាអំពីបញ្ហានោះ ហើយស្នើសុំជំនួយ។ នាយកសាលាអាចស្វែងរកការទ្រទ្រង់ពីភ្នាក់ងារទំនាក់ទំនងសាលា និងផ្ទះ ឬភ្នាក់ងារទំនាក់ទំនងសិស្សអាបូរីជីនី។

## តើនរណាជាភ្នាក់ងារទំនាក់ទំនងសាលា និងផ្ទះ ឬភ្នាក់ងារទំនាក់ទំនងសិស្សអាបូរីជីនី?

ភ្នាក់ងារទំនាក់ទំនងសាលា និងផ្ទះ ឬភ្នាក់ងារទំនាក់ទំនងសិស្សអាបូរីជីនី បានទទួលការហ្វឹកហ្វឺនពិសេសសំរាប់ជួយលោកអ្នកជាមួយនឹងការទៅរៀនរបស់កូនលោកអ្នក។

គេធ្វើការជាមួយសហគមន៍សាលា ដើម្បីលើកទឹកចិត្តសិស្សទាំងអស់ទៅសាលារៀនឲ្យបានទៀងទាត់។

ចំពោះព័ត៌មានបន្ថែមអំពីកម្មវិធីទំនាក់ទំនងសាលា និងផ្ទះ លោកអ្នកគួរទាក់ទងជាមួយនាយកកម្មវិធីនៅការិយាល័យប្រចាំតំបន់នៃក្រសួងអប់រំ និងហ្វឹកហ្វឺន។ លេខទូរស័ព្ទទំនាក់ទំនងអាចរកបាននៅតាមវ៉ិបសាយៈ www.det.nsw.edu.au/contactus/index.htm ឬដោយទូរស័ព្ទលេខ 131 536។

## តើលោកអ្នកមានបញ្ហាក្នុងការនាំកូនរបស់លោកអ្នកទៅសាលារៀន ដោយសារមូលហេតុខ្លះដូចតទៅនេះឬទេ?

- ពុំព្រមងើបចេញពីគ្រែ
- ពុំព្រមទៅគេង
- មិនរកឃើញសម្លៀកបំពាក់ សៀវភៅ កិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះ ការបូបសាលា...
- មិនទាន់បានរៀបចំអាហារថ្ងៃត្រង់
- បរិភោគអាហារពេលព្រឹកយឺតយូរ
- មិនបានបំពេញកិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះ
- មើលទូរទស្សន៍នៅពេលយប់ជ្រៅ ឬនៅពេលគេត្រូវប្រុងប្រៀបខ្លួនដើម្បីធ្វើតេស្តនៅសាលារៀន
- ធ្វើការសម្តែងឲ្យមើលនៅពេលថ្ងៃខួបសាលា
- បុណ្យខួបកំណើត
- ស្រែកដាក់លោកអ្នកមិនចេះឈប់។

## នេះគឺជាយោបល់ខ្លះៗដែលផ្អែកទៅលើការរៀបចំជាទម្លាប់ទៀងទាត់ៈ

- កំណត់ម៉ោងដើម្បីឲ្យងើបចេញពីគ្រែ
- កំណត់ម៉ោងដើម្បីឲ្យចូលគេង
- រៀបចំឯកសណ្ឋានសាលា និងកាបូបសាលាឲ្យរួចស្រេចពីយប់
- ធ្វើអាហារថ្ងៃត្រង់ឲ្យរួចស្រេចពីយប់
- កំណត់ម៉ោងការចាប់ផ្តើម / ការបង្ហើយអាហារពេលព្រឹក។ ការឲ្យមានទម្លាប់គឺជាការសំខាន់
- កំណត់ម៉ោងសំរាប់សកម្មភាពកិច្ចការសាលាគ្រូដាក់ឲ្យធ្វើនៅផ្ទះប្រចាំថ្ងៃ
- បើកទូរទស្សន៍ទៅតាមពេលម៉ោងដែលកំណត់ ហើយប្រសិនបើជាការសមស្របប៉ុណ្ណោះ
- ត្រូវឲ្យបានម៉ឺងម៉ាត់ ក្មេងត្រូវទៅរៀន
- ផ្តល់ការលើកទឹកចិត្តជាវិជ្ជមានឲ្យបានច្រើន
- ត្រូវឲ្យបានម៉ឺងម៉ាត់ ថាថ្ងៃខួបកំណើតពុំមែនជាថ្ងៃឈប់សំរាកទេ
- កំណត់ម៉ោងមកដល់សាលារៀនឲ្យបានត្រូវគ្នានឹងម៉ោងកណ្តឹងរោទិ៍ ហើយចាកចេញឲ្យបានឆាប់។ ប្រសិនបើបានសំរួលជាមួយគ្រូទុកជាមុន សូមដាក់ដៃកូនរបស់លោកអ្នកទៅក្នុងដៃរបស់គ្រូរួចចាកចេញភ្លាម។

## តើលោកអ្នកត្រូវការអ្នកបកប្រែភាសាឬទេ?

កិច្ចបំរើបកប្រែភាសាមានផ្តល់ពេលណាអាចធ្វើទៅបានសំរាប់មាតាបិតា និងអ្នកមើលថែដែលមិននិយាយឬយល់ភាសាអង់គ្លេសល្អ និងសំរាប់មាតាបិតា និងអ្នកមើលថែគថ្លង់ដែលប្រើសញ្ញាជាភាសា។ ចំពោះព័ត៌មានបន្ថែមអំពីកិច្ចបំរើអ្នកបកប្រែភាសា សូមទាក់ទងជាមួយសាលារៀនរបស់លោកអ្នក ឬទូរស័ព្ទទៅកិច្ចបំរើអ្នកបកប្រែភាសាតាមទូរស័ព្ទ ហើយស្នើសុំឲ្យគេទាក់ទងជាមួយសាលារៀន។ លេខទូរស័ព្ទគឺ 131 450។ សូមសួររកអ្នកបកប្រែភាសាដែលលោកអ្នកត្រូវការ ហើយអ្នកបកប្រែភាសានោះនឹងទូរស័ព្ទមកសាលារៀន ហើយនៅរង់ចាំតាមទូរស័ព្ទដើម្បីជួយលោកអ្នកនៅក្នុងការសន្ទនារបស់លោកអ្នក។ គេនឹងមិនគិតថ្លៃលោកអ្នកសំរាប់កិច្ចបំរើនេះទេ។

© March 2010
Student Welfare Directorate
NSW Department of Education & Training